រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

# ការអនុវត្តន៍ល្អ

## ការឈប់សំរាកឈឺ

កម្មករគ្រប់រូបមានសិទ្ធិឈប់សំរាកឈឺ។ និយោជកត្រូវផ្តល់កម្មករនូវការឈប់សំរាកឈឺ ព្រមទាំងការឈប់សំរាកឈឺមានប្រាក់ឈ្នួល ដូចមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុង។ សុខភាពកម្មករមានសារៈសំខាន់ណាស់ដល់ផលិតភាពរបស់សហគ្រាស។ ត្រូវរៀបចំប្រើប្រាស់នីតិវិធីឈប់សំរាកឈឺឱ្យបានច្បាស់លាស់ ដើម្បីធានាឱ្យមានការសហការល្អនៅកន្លែងការងារ និងប្រសិទ្ធិភាពការងារ។

### ការអនុវត្តន៍ល្អសំរាប់ការឈប់សំរាកឈឺ

- ត្រូវផ្តល់ឱ្យកម្មករនូវការឈប់សំរាកឈឺមានប្រាក់ឈ្នួលរហូតដល់រយៈពេល ៦ ខែ នៅពេលដែលគេបានអវត្តមានពីការងារដោយសារតែមានជំងឺរ៉ាំរ៉ៃ/ធ្ងន់ធ្ងរ ព្រមទាំងមានសំបុត្រពេទ្យពីវេជ្ជបណ្ឌិតស្របច្បាប់ផង (រូបភាពទី ១)។
- បន្ថែមលើនេះទៀត គួរផ្តល់ការឈប់សំរាកឈឺមានប្រាក់ឈ្នួលដល់កម្មករចំនួន ៧ ថ្ងៃក្នុងមួយឆ្នាំសំរាប់ការឈឺមានរយៈពេលខ្លី ដោយមិនចាំបាច់មានសំបុត្រពេទ្យ។
- ត្រូវធានាថា មិនមានការរឹតបណ្តឹងដោយមិនសមហេតុផលលើកម្មករក្នុងការសុំឈប់សំរាកឈឺ។
- ត្រូវទិញការធានារ៉ាប់រងសំរាប់កម្មករនិយោជិត។
- ត្រូវផ្តល់សេវាកម្មសុខភាពនៅកន្លែងការងារ និងចាត់វិធានការបង្ការរាល់សារធាតុពុល រាល់ហានិភ័យដល់សុខភាព និងសុវត្ថិភាព និងរោគឆ្លងរាតត្បាតផ្សេងៗដូចជាហ៊ីវ/អេដស៍ និងគ្រុនផ្តាសាយបក្សី (រូបភាពទី ២)។
- ក្នុងករណីមានអាសន្ន ត្រូវបញ្ជូនកម្មករដែលមានជំងឺធ្ងន់ធ្ងរ ឬរងរបួសទៅកាន់មន្ទីរពេទ្យនៅជិតបំផុត។
- ដើម្បីធានាឱ្យកាន់តែមានល័ក្ខខ័ណ្ឌសុខភាពល្អ ត្រូវផ្តល់ការឈប់សំរាក និងការសំរាកក្រោយងើបពីឈឺសំរាប់កម្មករ (រូបភាពទី ៣)។
- ត្រូវគោរពសេចក្តីត្រូវការរបស់កម្មករមានផ្ទៃពោះ និងកម្មករពិការ។


រូបភាពទី១


រូបភាពទី២


រូបភាពទី៣

### អត្ថប្រយោជន៍:

- ✓ ការឈប់សំរាកឈឺ នឹងអាចឆាប់ជាសះស្បើយរឹងមាំ រីឯការព្យាបាលភ្លាមៗនឹងកាត់បន្ថយករណីធ្ងន់ធ្ងរ ក៏ដូចជាកាត់បន្ថយចំណាយលើការព្យាបាល និងអវត្តមានយូរអង្វែង
- ✓ ការគាំពារដល់សុខុមាលភាពកម្មករ នឹងពង្រឹងការស្មោះស្ម័គ្រលើសហគ្រាស
- ✓ ការពេញចិត្តរបស់កម្មករមានកំរិតខ្ពស់ ធ្វើឱ្យការលាឈប់ពីការងារ នឹងមានកំរិតទាប ព្រមទាំងនឹងឈានដល់ការកែលំអផលិតភាព
- ✓ ការបង្ការជាប្រចាំ គឺជាមធ្យោបាយនៃប្រសិទ្ធិភាពចំណាយដើម្បីលើកស្ទួយសុខភាពរបស់កម្មករ
- ✓ កម្មករមានសុខភាពល្អ នឹងបង្កើនសន្ទុះការងារ

### តាមរបៀបណា:

- ✓ ត្រូវរៀបចំ និងអនុវត្តគោលនយោបាយស្តីពីសុវត្ថិភាព និងសុខភាពការងារសំរាប់សហគ្រាស
- ✓ ត្រូវបញ្ចូលការឈប់សំរាកឈឺមានប្រាក់ឈ្នួលទៅក្នុងបទបញ្ជាផ្ទៃក្នុង និងគោលនយោបាយរបស់សហគ្រាស
- ✓ ត្រូវផ្តល់ប្រាក់ឈ្នួលក្នុងអំឡុងពេលមានជំងឺដោយអនុលោមទៅតាមច្បាប់ការងារ
- ✓ ត្រូវរៀបចំឱ្យមានគិលានដ្ឋាននៅជិតកន្លែងការងារ និងបំពាក់ដោយឧបករណ៍ព្យាបាលឱ្យបានគ្រប់គ្រាន់ មានបុគ្គលិកគ្រប់គ្រាន់ និងមានសមត្ថភាពព្យាបាលកម្មករមានជំងឺ
- ✓ ត្រូវទិញការធានារ៉ាប់រងសំរាប់សហគ្រាសពាក់ព័ន្ធនឹងគ្រោះថ្នាក់ការងារ និងជំងឺការងារ
- ✓ ត្រូវត្រៀមជាស្រេចសំរាប់ភាពមានអាសន្ន ដោយផ្តល់ការបណ្តុះបណ្តាលស្តីពីការសង្គ្រោះបឋម ការហ្វឹកហាត់ពេលមានអគ្គីភ័យ និងជំលៀសខ្លួនចេញ
- ✓ រក្សាកំណត់ហេតុគ្រោះថ្នាក់ និងជំងឺ និងប្រកាសប្រាប់ដល់អាជ្ញាធរពាក់ព័ន្ធតាមពេលវេលាបានកំនត់

**តំលៃ:**

$

$ តំលៃទាប

$$ តំលៃមធ្យម

$$$ តំលៃខ្ពស់